**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ១១.០៥០/០៧ គ.ជ.ប.អគ្គ.៣ស** ភ្នំពេញ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៧

# ក្រុមប្រឹក្សាធម្មនុញ្ញ តម្កល់សេចក្តីសម្រេចរបស់ គ.ជ.ប

ក្រុមប្រឹក្សាជំនុំជំរះ នៃក្រុមប្រឹក្សាធម្មនុញ្ញ បានបដិសេធបណ្តឹងរបស់តំណាងគណបក្សសម រង្ស៊ី ចំនួន ២ បណ្តឹង ដែលគណបក្សនេះ បានប្តឹងតវ៉ា ក្នុងនោះ មួយបណ្តឹងបានតវ៉ាសុំលុបឈ្មោះចំនួន ២.០៣៣ នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូង នៅឃុំ ព្រែកជ្រៃ និងឃុំ សំពៅពូន ក្នុងស្រុកកោះធំ ខេត្ត កណ្តាល និងបណ្តឹងមួយទៀតបានប្តឹងសុំរក្សាទុកឈ្មោះចំនួន ៣.២៤៤ នាក់ នៅក្នុងបញ្ជីបោះឆ្នោតដំបូង សង្កាត់គីឡូម៉ែតលេខ ៦ ក្រុងភ្នំពេញ។

បណ្តឹងទាំងពីរ ដែលក្រុមប្រឹក្សាជំនុំជំរះបដិសេធនេះ ទី១ ជាបណ្តឹងរបស់លោក ឡុង លឹមហ៊ា តំណាងគណបក្សសម រង្ស៊ី បានប្តឹងសុំលុបឈ្មោះចំនួន ១.៣៣១ នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូង នៅឃុំព្រែកជ្រៃ និងសុំលុបឈ្មោះ ៧០២ នាក់ នៅឃុំសំពៅពូន ដោយសំអាងថា ឈ្មោះទាំងនេះ ជាជនជាតិវៀតណាម ពុំមានសញ្ជាតិខ្មែរ និងគ្មានទីលំនៅច្បាស់លាស់ ។ បណ្តឹងនេះ ត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញ ធ្វើការជំនុំជំរះនៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ហើយនៅក្នុង អង្គសវនាការ លោក ឡុង លឹមហ៊ា ពុំមានភស្តុតាងជាលាយលក្ខណ៍អក្សរ ណាមួយបញ្ជាក់ចំពោះមុខអង្គសវនាការឡើយ ទើបក្រុមប្រឹក្សាជំនុំជំរះ សម្រេចបដិសេធបណ្តឹងនេះចោល និងតម្កល់សេចក្តីសម្រេចរបស់ គ.ជ.ប ទុកជាបានការត្រឹមត្រូវតាមគតិច្បាប់ ។

ទី២ ជាបណ្តឹងរបស់លោក លី សុវិជ្ជា តំណាងគណបក្សសម រង្ស៊ី បានប្តឹងសុំរក្សាទុកឈ្មោះចំនួន ៣.២៤៤ នាក់ ក្នុងបញ្ជីបោះឆ្នោតដំបូងនៅសង្កាត់គីឡូម៉ែតលេខ ៦ ។ បណ្តឹងនេះត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញ ធ្វើការជំនុំជំរះ នៅថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ហើយនៅក្នុងសវនាការលោក លី សុវិជ្ជា ពុំមានភស្តុតាងជាលាយលក្ខណ៍អក្សរ ណាមួយបញ្ជាក់ចំពោះមុខអង្គសវនាការដែរ ទើបក្រុមប្រឹក្សាជំនុំជំរះ សម្រេចបដិសេធបណ្តឹងនេះចោល និងតម្កល់សេចក្តីសម្រេចសវនាការរបស់ គ.ជ.ប ទុកជាបានការត្រឹមត្រូវតាមគតិច្បាប់ ។

សូមបញ្ជាក់ថា បណ្តឹងទាំងពីរនេះ គ.ជ.ប បានបើកសវនាការជាសាធារណៈ កាលពីថ្ងៃ ៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ហើយបានបដិសេធចោលបណ្តឹងទាំងនេះ ដោយសារដើមបណ្តឹងគ្មានភស្តុតាងគ្រប់គ្រាន់ ។